ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ..៣៤៧ សជណ./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី..០៩. ខែកញ្ញា ឆ្នាំ២០១១.

**សូមជម្រាបជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ការបែងចែកថវិកាបន្ថែមសម្រាប់កសាងសមត្ថភាពថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រដល់ថ្នាក់ឃុំ សង្កាត់។

**យោង** : ផែនការសកម្មភាព និងថវិកាឆ្នាំ ២០១១ និងលិខិតលេខ៣២១ ស.ជ.ណ/គ.ជ.អ.ប ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបឯកឧត្តមជ្រាបថា មុខងារគាំទ្រដល់ឃុំ សង្កាត់ ត្រូវបានផ្ទេរពីថ្នាក់រាជធានី ខេត្ត ទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ។ ដោយសារមុខងារនេះ គឺជាមុខងារថ្មីសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងដោយមានមន្ត្រីថ្មីជាច្រើននៅក្នុងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ពុំទាន់មានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ ចាំបាច់រាជធានី ខេត្តនីមួយៗត្រូវយកចិត្តទុកដាក់លើការកសាងសមត្ថភាពដល់មន្ត្រីទាំងនោះ។

ផ្អែកលើផែនការបណ្តុះបណ្តាលដែលរាជធានី ខេត្តនីមួយៗបានរៀបចំកន្លងមក លេខាធិការដ្ឋាន គ.ជ.អ.ប សូមផ្តល់ថវិកាបន្ថែមលើថវិកាដែលមានស្រាប់ សម្រាប់ការបណ្តុះបណ្តាលនេះ ដូចមានក្នុងតារាងជូនភ្ជាប់មកជាមួយ។

ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលនេះ រាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់លើកិច្ចការមួយចំនួន ដូចខាងក្រោម :

**១). សិក្ខាកាម :**

សិក្ខាកាមដែលត្រូវចូលរួម គឺជាទីប្រឹក្សាគ្រប់គ្រងកម្មវិធីថ្នាក់ក្រុង ស្រុក ខណ្ឌ មន្ត្រីទាំងឡាយណាដែលស្ថិតនៅក្នុងក្របខ័ណ្ឌចំណាយប្រតិបត្តិការអាទិភាព (POC) និងមន្ត្រីនៅថ្នាក់រដ្ឋបាលដែលរំពឹងថានឹងផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់។

**២). ប្រធានបទចាំបាច់ដែលត្រូវធ្វើការបណ្តុះបណ្តាល :**

- សិក្ខាសាលាតម្រង់ទិសស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ផអ៣ រចនាសម្ព័ន្ធ និងប្រព័ន្ធគាំទ្រនានា ដើម្បីឱ្យមន្ត្រីដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការចំណាយ

ប្រតិបត្តិការអាទិភាព (POC) ដែលទើបជ្រើសរើស និងមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់មានការយល់ដឹងអំពីទស្សនទានសំខាន់ៗនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងរបៀបរបបធ្វើការងារក្នុងអង្គភាព។

- ការគាំទ្រដល់ដំណើរការរៀបចំកម្មវិធីវិនិយោគ និងការអនុវត្ត គម្រោងរបស់ឃុំ សង្កាត់ ត្រូវផ្តោតលើ :
  - ក) ការងារលទ្ធកម្មគម្រោងរបស់ឃុំ សង្កាត់ ការរៀបចំកិច្ចសន្យា និងការត្រួតពិនិត្យការអនុវត្តកិច្ចសន្យា ដោយប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោង។
  - ខ) ការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ សម្រាប់ឆ្នាំ ២០១២។
  - គ) ការងាររដ្ឋបាល និងហិរញ្ញវត្ថុឃុំ សង្កាត់ និងកិច្ចការសំខាន់ៗផ្សេងទៀត។
- គោលការណ៍ត្រួតពិនិត្យនិងវាយតម្លៃ និង ប្រព័ន្ធរបាយការណ៍របស់ ផអព និងព័ត៌មានវិទ្យា (ជំនាញក្នុងការប្រើប្រាស់កម្មវិធី បណ្តាញ និងសារអេឡិចត្រូនិច)។

ចំពោះមន្ត្រីគាំទ្របច្ចេកទេស លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំការបណ្តុះបណ្តាលមួយនៅថ្នាក់ជាតិដល់មន្ត្រីគាំទ្របច្ចេកទេសដែលមិនទាន់មានបទពិសោធន៍ ដោយមានកិច្ចសហការជិតស្និទ្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា។

**៣). ការងារសម្របសម្រួល និងការរៀបចំរបាយការណ៍ :**

ដោយមានជំនួយពីទីប្រឹក្សាកម្មវិធីថ្នាក់រាជធានី ខេត្ត រាជធានី ខេត្តត្រូវធានាថា សកម្មភាពដែលរៀបរាប់ខាងលើ ត្រូវបានពិភាក្សាបន្ថែមទៀតជាមួយទីចាត់ការ ការិយាល័យ និងភាគីផ្សេងទៀត ដែលពាក់ព័ន្ធនឹងប្រធានបទនៃការបណ្តុះបណ្តាល។ ជាមួយគ្នានេះដែរ រាល់ការបណ្តុះបណ្តាលនីមួយៗ ត្រូវធ្វើការកត់ត្រាឱ្យបានច្បាស់លាស់នូវលទ្ធផលដូចជា ចំនួនអ្នកចូលរួមជាបុរស និងស្ត្រី កម្រិតយល់ដឹងរបស់សិក្ខាកាម និង បញ្ហាប្រឈមដែលនឹងត្រូវប្រើជារបាយការណ៍នៃការបណ្តុះបណ្តាល។

**៤). ការចំណាយសម្រាប់ការបណ្តុះបណ្តាល :**

ការចំណាយសម្រាប់ការបណ្តុះបណ្តាលនេះ ត្រូវអនុលោមតាមគោលការណ៍រដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ ជាពិសេសអនុក្រឹត្យលេខ១០ របស់រាជរដ្ឋាភិបាលស្តីពីការកំណត់របបបេសកកម្មក្នុង និងក្រៅប្រទេស។

**៥).ការកែសម្រួលផែនការសកម្មភាពនិងថវិកាឆ្នាំ ២០១១ របស់រាជធានី ខេត្ត :**

ការរៀបចំវគ្គបណ្តុះបណ្តាលដែលរៀបរាប់ខាងលើ នឹងត្រូវធ្វើឡើងតាមរយៈការធ្វើវិសោធនកម្មនៃផែនការសកម្មភាព និងថវិកាឆ្នាំ២០១១របស់រាជធានី ខេត្តនីមួយៗ។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការណែនាំអំពីការធ្វើវិសោធនកម្មនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់ចែង និងអនុវត្តតាមស្មារតីនៃលិខិតនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ជ.ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ឈេង_ឡឺ**

**<u>ចំលងជូន:</u>**

- ប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីនៃ ផអ៣
- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

# ថវិកាសម្រាប់ការបណ្តុះបណ្តាលដើម្បីគាំទ្រឃុំ សង្កាត់

| | | រាជធានី ខេត្ត | ប្រធានបទទាក់ទងនឹងឃុំសង្កាត់និងការតម្រង់ទិសជអព | ការតាមដាននិងវាយតម្លៃ | ពត័មានវិទ្យា | Total in US$ |
|---|---|---|---|---|---|---|
| 1 | **BMC** | បន្ទាយមានជ័យ | 1,114 | 1,330 | 1,365 | 3,809 |
| 2 | **BAT** | បាត់ដំបង | 4,800 | 2,125 | 2,190 | 9,115 |
| 3 | **KPC** | កំពង់ឆ្នាំង | 4,809 | 2,602 | 2,645 | 10,056 |
| 4 | **KCH** | កំពង់ចាម | 4,127 | 1,171 | 1,180 | 6,478 |
| 5 | **KSP** | កំពង់ស្ពឺ | 1,962 | 1,171 | 1,180 | 4,313 |
| 6 | **KPT** | កំពង់ធំ | 3,632 | 1,171 | 1,180 | 5,983 |
| 7 | **KAM** | កំពត | 7,019 | 1,171 | 1,180 | 9,370 |
| 8 | **KDL** | កណ្តាល | 4,906 | 1,648 | 1,635 | 8,189 |
| 9 | **KKG** | កោះកុង | 989 | 1,012 | 1,095 | 3,096 |
| 10 | **KRT** | ក្រចេះ | 3,809 | 853 | 910 | 5,572 |
| 11 | **MKR** | មណ្ឌលគិរី | 5,522 | 694 | 350 | 6,566 |
| 12 | **PNP** | ភ្នំពេញ | 4,133 | 321 | 765 | 5,219 |
| 13 | **PVH** | ព្រះវិហារ | 1,284 | 1,171 | 1,180 | 3,635 |
| 14 | **PVG** | ព្រៃវែង | 9,500 | 1,966 | 2,005 | 13,471 |
| 15 | **PUR** | ពោធិសាត់ | 2,187 | 853 | 910 | 3,950 |
| 16 | **RAT** | រតនៈគិរី | 3,174 | 1,330 | 1,365 | 5,869 |
| 17 | **SRP** | សៀមរាប | 1,748 | 1,807 | 1,820 | 5,375 |
| 18 | **SHV** | ព្រះសីហនុ | 994 | 535 | 540 | 2,069 |
| 19 | **STG** | ស្ទឹងត្រែង | 1,329 | 694 | 725 | 2,748 |
| 20 | **SVR** | ស្វាយរៀង | 6,747 | 1,171 | 1,180 | 9,098 |
| 21 | **TAK** | តាកែវ | 1,994 | 1,489 | 1,550 | 5,033 |
| 22 | **OMC** | ឧត្តរមានជ័យ | 3,491 | 694 | 725 | 4,910 |
| 23 | **KEP** | កែប | 592 | 104 | 170 | 866 |
| 24 | **PLN** | ប៉ៃលិន | 748 | 104 | 170 | 1,022 |
| | | សរុប | **80,610** | **27,187** | **28,015** | **135,812** |